# នយោបាយភាសា ៖ បរិបទ កម្ពុជា សិង្ហបុរី និង ចិន

Politics of language: Context in Cambodia, China, and Singapore

**បណ្ឌិត ខង់ មេង**
អនុប្រធានវិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា
អ៊ីមែល ៖ mengifl@gmail.com

## ១- សេចក្តីផ្តើម

ភាសាគឺជាស្នូលនៃវប្បធម៌ ពីព្រោះភាសាគឺជាប្រព័ន្ធគំនិតនៅក្នុងទំនាក់ទំនងសង្គម ហើយ ភាសាក៏ជាប្រព័ន្ធគំនិតដែលត្រូវយកមកប្រើប្រាស់ដើម្បីគ្រប់គ្រងប្រទេស ដើម្បីឱ្យសមស្របទៅតាមនិន្នាការនយោបាយរបស់ប្រទេសនីមួយ ។ ការគ្រប់គ្រងប្រទេសមួយឱ្យបានល្អ ត្រូវស្គាល់ផ្នត់គំនិតនៃសង្គម ម្យ៉ាងដើម្បីយល់អំពីវប្បធម៌របស់ជាតិមួយ ចាំបាច់ណាស់ត្រូវយល់អំពីភាសា។ ក្នុងកិច្ចការស្រាវជ្រាវនេះ វិធីសាស្ត្រប្រៀបធៀបបានយកមកអនុវត្ត ដោយផ្តើមចេញពីការរៀបចំនយោបាយភាសាជាតិខ្មែរ បទពិសោធប្រទេសសិង្ហបុរី និង ប្រទេសចិន ។ គោលវិធីបួនដែលត្រូវយកមកប្រើប្រាស់ក្នុងវិធីសាស្ត្រប្រៀបធៀបនោះគឺ ភាសា អត្តសញ្ញាណជាតិ ស្តង់ដាភាសា និង យោបាយ ។ គោលបំណងសំខាន់នៃកិច្ចការស្រាវជ្រាវនេះ គឺបង្ហាញអំពីទិដ្ឋភាពគោលនយោបាយទៅលើភាសាក្នុងកម្រិតជាតិ កម្រិតតំបន់ និង កម្រិតអន្តរជាតិ ។

ក្រោយឆ្នាំ ១៩៧៩ ប្រទេសកម្ពុជា បានអភិវឌ្ឍភាសាជាតិរបស់ខ្លួនឡើងវិញ បន្ទាប់ពីទទួលរងសោកនាដកម្មអស់ ៣ ឆ្នាំ ៨ ខែ និង ២០ ថ្ងៃ ក្នុងរបបអាវខ្មៅ ។ ក្រោយឆ្នាំ ១៩៧៩ នោះទៀតសោត ប្រជាជនខ្មែរខ្លះ បើកស្តាប់វិទ្យុបរទេស ប្រាកដជាខាងរដ្ឋអំណាច ភូមិ ឃុំ ជំនាន់នោះ មកណែនាំដល់ផ្ទះដែរ ។ ចំណែកឯនៅប្រទេសតួគីវិញ នៅឆ្នាំ ១៩៩១ ជនជាតិឃើតនៅប៉ែកខាងត្បូងនៃប្រទេសតួគី មិនអាចនិយាយភាសារបស់គេបានទេ ប្រសិនបើជនជាតិឃើត ហ៊ានតែនិយាយភាសារបស់គាត់ ពួកគាត់នឹងត្រូវចាប់ខ្លួនដាក់ក្នុងមន្ទីរឃុំឃាំងហើយ ។ ប៉ុន្តែក្រោយមក នៅឆ្នាំ២០០២ ក្រុមនិស្សិតដែលត្រូវគេចាប់ដាក់គុក បានទាមទារឱ្យមានការបង្រៀនភាសាឃើតនៅតាមសាលារៀន ដើម្បីកុំឱ្យមានការរើសអើងប្រកាន់ពូជសាសន៍ ។ នៅឆ្នាំ ២០០២ នៅប្រទេសសិង្ហបុរី រដ្ឋាភិបាលសិង្ហបុរី បានហាមឃាត់រឿងមួយមិនឱ្យបញ្ចាំងតាមកញ្ចក់ទូរទស្សន៍ រឿងនោះគឺ Little Red Riding Hood ដោយសាររឿងនេះ មានឃ្លាប្រយោគមិនគោរពទៅតាមក្បួនខ្នាតវេយ្យាករណ៍ ។ ប្រទេសចិនវិញ នៅឆ្នាំ២០០៤ រដ្ឋាភិបាលចិន ក៏មិនអនុញ្ញាតឱ្យបញ្ចាំងរឿងតុក្កតា « ឆ្មា និង កណ្តុរ » ដែរ ដោយសាររឿងនោះ បានយកពាក្យពេចន៍របស់អ្នកស្រុក ស៊ាង ហៃ ទៅប្រើប្រាស់ជំនួសភាសាចិនកុកងឺ ។ ទាំងអស់នេះ ឆ្លុះបញ្ចាំងអំពីនយោបាយរបស់រដ្ឋាភិបាល ក្នុងការគ្រប់គ្រងប្រទេស ដើម្បីស្របតាមគោលនយោបាយរៀងៗខ្លួន ។

រចនាសម្ព័ន្ធនៃការស្រាវជ្រាវនេះ នឹងស្វែងរកគោលគំនិតបីសំខាន់។ ទីមួយ សំណេរនេះនឹងផ្តោតសំខាន់ទៅលើនយោបាយនិងភាសា ដែលមានការជាប់ទាក់ទងទៅនឹងភាសានិងអត្តសញ្ញាណ និងបច្ចេកស័ព្ទពាក់ព័ន្ធមួយចំនួន។ គោលគំនិតសំខាន់ទីពីរ អត្ថបទស្រាវជ្រាវនេះ នឹងពិពណ៌នាអំពីស្តង់ដានីយកម្មភាសា ដោយឆ្លុះបញ្ចាំងអំពីការរៀបចំភាសាមួយដើម្បីបង្កើតស្តង់ដាជាតិ ហើយ ក្នុងនោះ ក៏មានការលើកឡើងអំពីប្រទេសកម្ពុជា សិង្ហបុរី និង ចិន ។ ចំណុចចុងក្រោយទីបី អត្ថបទនេះ នឹងអត្ថាធិប្បាយអំពីនយោបាយនៃស្តង់ដានីយកម្មភាសា ដោយទាក់ទងទៅនឹងទ្វេភាសា ភាសានិងយោបាយ និង សិទ្ធិភាសា។

## ២- នយោបាយ និង ភាសា

នៅទីនេះ យើងលើកយកបញ្ហាពីរសំខាន់ៗយកមកពិភាក្សា ពោលគឺ **នយោបាយភាសា** (politics of language) និង **ភាសានយោបាយ** (Language of politics) ។

**នយោបាយភាសា** សំដៅទៅលើដំណើរការនៃការជជែកដេញដោល និង សេចក្តីសម្រេចចិត្តផ្អែកលើទិដ្ឋភាពនៃគោលនយោបាយភាសា ដោយទាក់ទងទៅនឹង ភាសាផ្លូវការ ភាសាស្តង់ដា ភាសាងាយរងគ្រោះ ផែនការភាសា បណ្ឌិតសភាភាសា និង ការផ្តួចផ្តើមកម្មវិធីសិក្សាអប់រំ ។ ចំណែកឯ **ភាសានយោបាយ** វិញ សំដៅដល់ភាសា និង សំនួន ដែលបានប្រើប្រាស់នៅក្នុងជីវិតសាធារណៈ ហើយ ជាពិសេស ប្រើដោយអ្នកនយោបាយ (ស្វន [Swann et al.] និង ដទៃទៀត ២០០៤ ទំព័រ ២៤៤)។

ភាសាក៏អាចចាត់ទុកថាជារឿងនយោបាយផងដែរ ពីព្រោះថា «*ភាសា គឺជាមធ្យោបាយរបស់បុគ្គលហើយភាសារបស់បុគ្គលនោះទៀតសោតឆ្លុះបញ្ចាំងអំពីតម្លៃរបស់មនុស្សដែលជាសមាជិករបស់សង្គម*» (ដេសាល់ [Desalles] ២០០០ ទំព័រ ៣៣២)។ ត្រង់ចំណុចនេះ លោក អារីស្តូត ក៏បាន គូសបញ្ជាក់ផងដែរថា ៖ «*ធម្មជាតិ បង្កើតមនុស្ស ហើយ មនុស្ស គឺជាសត្វមួយប្រភេទប៉ុណ្ណោះ ដែលអាចប្រើសម្តី* » (អារីស្តូត នយោបាយ [បកប្រែដោយ ជូវេត (Jowett)] ១៨៨៥)។ មិនត្រឹមតែប៉ុណ្ណោះ ភាសាបានបង្កើតអត្តសញ្ញាណរបស់មនុស្ស អត្តសញ្ញាណសង្គម ដើម្បីធ្វើឱ្យមនុស្សបង្ហាញអំពីកក្តីភាពរវាងគ្នានៅក្នុងសង្គមមួយ ដោយតបស្នងមកវិញដោយការយកចិត្តទុកដាក់របស់រដ្ឋាភិបាលចំពោះប្រជាពលរដ្ឋរបស់ខ្លួននៅក្នុងសង្គមនោះ (ផាសូល [Fasold] ២០០៦ ទំព័រ ៣៧៥)។ អាស្រ័យហេតុហើយ ភាសា គឺជាផ្នែកមួយយ៉ាងធំរបស់នយោបាយ ។

ដើម្បីផ្សារភ្ជាប់ទៅនឹងគោលគំនិតខាងលើ បញ្ញត្តិចំនួន ៤ នឹងលើកយកមកពិភាក្សាផងដែរ គឺ ជនជាតិ (nationality) ក្រុមជាតិពន្ធុ (Ethnic Group) ជាតិនិយម (nationalism) ប្រជាជាតិនិយម (nationism) ។ **ជនជាតិ** សំដៅលើក្រុមសង្គមដែលមានកម្រិតនៃសង្គមចម្រុះហើយមានការជាប់ទងគ្នា ។ ជនជាតិ អាចមាន ឬ មិនអាចមានការគ្រប់គ្រងបូរណភាពដែនដីជាអធិបតីជាតិរបស់ខ្លួន ឧទាហរណ៍ ជនជាតិ បាសនៅប្រទេសអេស្ប៉ាញ ជនជាតិឃើតនៅប្រទេសអ៊ីរ៉ាក់ ជាដើម ។ លើសពីនេះទៅទៀត ជនជាតិ មានលក្ខណៈសម្បត្តិចំនួន ៣ សំខាន់ ដែលគេចាត់ទុកថាជានិម្មិតរូបនៃអត្តសញ្ញាណជាតិរបស់ពួកគេ ពោលគឺ ភាសា សាសនា និង

បូរណភាពដែនដី ។ រីឯ **ក្រុមជាតិពន្ធុ** មានការជាប់ទាក់ទងដំបូងទៅនឹងកិច្ចការផ្ទៃក្នុងរបស់ខ្លួន និង មិនមានផលប្រយោជន៍ច្រើននៅក្នុងអង្គភាពសង្គមរបស់ពួកគាត់ទេ លើកលែងតែមានអ្នកជិតស្និទ្ធ ។ ក្រុមជាតិពន្ធុ អាចមិនដឹងថាប្រទេសណាមួយដែលគាត់រស់នៅឱ្យពិតប្រាកដនោះទេ (ផាសូល [Fasold] ២០០៦ ទំព័រ ៣៧៦)។

**ជាតិនិយម** ទាក់ទងទៅនឹងអត្តសញ្ញាណរបស់មនុស្ស ការយល់ដឹងខ្លួនឯងថាជាមនុស្សដែលបានរួបរួមគ្នាជាផ្លុងមួយ ហើយ ក្រុមមនុស្សនេះ អាចញែកខ្លួនឯងឱ្យខុសអំពីអ្នកដទៃបាន ។ អ្នកជាតិនិយម ឬ ភាសាជាតិ ទាក់ទងសំខាន់ទៅនឹងនិម្មិតរូប មានន័យថា ***ភាសាជាតិ*** គឺជានិម្មិតរូបនៃអត្តសញ្ញាណជាតិ ដោយផ្អែកទៅលើតម្លៃ តម្លៃនេះហើយមានតួនាទីសំខាន់ជានិម្មិតរូប ច្រើនជាង មុខងារ ។ ចំណែកឯ ប្រជាជាតិនិយមវិញ សំដៅដល់សេចក្តីលំអិតនៃការគ្រប់គ្រង ពីព្រោះថា ***ភាសាប្រជាជាតិនិយម*** ឬ ហៅម្យ៉ាងទៀតថា ***ភាសាផ្លូវការ*** គឺជាភាសាដែលយកមកប្រើដើម្បីអនុវត្តនៅក្នុងការងាររដ្ឋាភិបាល ដូចជា ឯកសារពន្ធដារ នីតិបញ្ញត្តិ កិច្ចការយោធា អប់រំក្មេងជាដើម ។ ភាសាផ្លូវការ ត្រូវគេយកមកប្រើជាភាសាអតីតអំណាចរបស់អាណានិគម ។

## ២.១- ប្រទេសកម្ពុជា

ភាសាខ្មែរ គឺជាភាសាផ្លូវការរបស់ជនជាតិខ្មែរភាគច្រើន ហើយ ការសិក្សាអប់រំភាគច្រើន ក៏ប្រើប្រាស់ភាសាខ្មែរផងដែរ ដោយកម្មវិធីសិក្សានៅកម្រិតចំណេះដឹងទូទៅ និង ក្រៅប្រព័ន្ធយកភាសាខ្មែរជាយាន ពីក្រសួងអប់រំ យុវជន និង កីឡា ។ ប្រទេសកម្ពុជា មាន **យោបាយ** (គ្រាមភាសា) ចំនួន ២៤ ក្នុងនោះ យោបាយចំនួន ៦ ត្រូវបានអនុម័តឱ្យមានការប្រើប្រាស់នៅតាមសហគមន៍និងថ្នាក់រៀន តាមរយៈគោលនយោបាយអប់រំភាសារបស់ក្រសួងអប់រំ យុវជន និង កីឡា សហការជាមួយនឹងអង្គការយូណេសែស ក្នុងនោះមាន យោបាយព្នង យោបាយគ្រឹង យោបាយប្រៅ យោបាយទំពួន និង យោបាយក្រាវែត (នៅ ស៊ុន ២០០៩ ទំព័រ ៦២) ។ ក្រៅពីនេះ ភាសាបរទេសជាច្រើនទៀតបានត្រូវសិក្សាក្នុងប្រទេស មានដូចជា ភាសាអង់គ្លេស ភាសាថៃ ភាសាជប៉ុន ភាសាកូរ៉េ ភាសាចិន ជាដើម ។

## ២.២- ប្រទេសសិង្ហបុរី

សាធារណរដ្ឋសិង្ហបុរី មានភាសាចំនួន ២៤ ដោយមានភាសាផ្លូវការចំនួន ៤ គឺ ភាសាអង់គ្លេស ភាសាចិន ភាសាម៉ាឡេ និង ភាសាតាមិល ។ ប្រទេសមួយនេះ មានជនជាតិដើមភាគតិចមករស់នៅ ដូចជា ជនជាតិចិនភាគច្រើនដែលមានដើមកំណើតមកអំពីចិនភាគខាងត្បូង ជនជាតិឥណ្ឌា និង ជនជាតិម៉ាឡេ ។ ប្រទេសសិង្ហបុរី មានផ្តល់ឱ្យមានកម្មវិធីនៃការគ្រប់គ្រងភាសា និង ផែនការភាសាច្បាស់លាស់ ដើម្បីលើកទឹកចិត្តដល់សាធារណជន ពីព្រោះ រដ្ឋាភិបាលសិង្ហបុរី ក៏បង្កើតគោលនយោបាយដ៏សំខាន់មួយសម្រាប់ប្រទេសជាតិ គឺគោលនយោបាយ**ពហុភាសានិយម** (multilingualism) នៅក្នុងសង្គម ។ លើសពីនេះទៅទៀត រដ្ឋាភិបាលសិង្ហបុរី ក៏បានជម្រុញកម្មវិធីទ្វេភាសាសម្រាប់ពលរដ្ឋរបស់ខ្លួនថែមទៀត ដើម្បីលើកស្ទួយចំណេះដឹងដល់ប្រជាពលរដ្ឋ ក្នុងប្រទេស (ស៊ីមសិន [Simpson] ២០០៧ ទំព័រ ៣៧៤) ។

## ២.៣- ប្រទេសចិន

ទឹកដីប្រទេសចិនទាំងមូល មានភាសាចំនួន ២០០ ក្នុងនោះ ភាសាចិនកុងងឺ (ពុតុងហ័រ [Putonghua]) គឺជាភាសាស្តង់ដាទំនើបរបស់ប្រទេសចិន ចំណែកនៅកោះតៃវ៉ាន ភាសាចិនមានចំនួន ២១ នៅកោះតៃវ៉ាន ភាសាចិនទំនើបនៅស្រុកនោះ គេហៅថា គ័រយូ (Guoyu)។ ក្រោយការបង្កើតសាធារណរដ្ឋប្រជាមានិតចិន នៅឆ្នាំ ១៩៤៩ ភាសាចិនទំនើបបានអភិវឌ្ឍជាលំដាប់ ។ ជាពិសេសទៅទៀតនោះ អ្នកប្រាជ្ញ និង រដ្ឋាភិបាលចិន បានយកចិត្តទុកដាក់លើកកិត្យានុភាពខាងចំណេះដឹងភាសាជាតិ និង ការប្រើប្រាស់ភាសាចិនកុងងឺទទួលបានជោគជ័យ ។ ដោយការខិតខំប្រឹងប្រែងរបស់អ្នកជំនាញខាងភាសា និង រដ្ឋាភិបាល ការយល់ដឹង និង ប្រើប្រាស់ភាសាចិនកុងងឺ បានជ្រួតជ្រាបដល់ស្រទាប់មហាជន ដោយសម្រេចបានសុច្ចនាករ ៩០ % ដែលប្រជាជនយល់អំពីភាសាចិនកុងងឺ ។

## ៣- ស្តង់ដានីយកម្មភាសា (Language Standardization)

ស្តង់ដានីយកម្មភាសា គឺជានានាភាពនៃភាសាដែលរួមមាន ភាសាដែលមានទម្រង់សំណេរ ភាសាដែលបានប្រើប្រាស់នៅក្នុងវចនានុក្រម និង វេយ្យាករណ៍ ការចេះអាន និង ការចេះសរសេរភាសា ការអប់រំ រដ្ឋាភិបាល រដ្ឋបាល ព័ត៌មានូបករណ៍ និង និម្មិត្តកម្មដែលមានកិត្យានុភាព (ចូសេប [Joseph] ១៩៨៧)។ ស្តង់ដានីយកម្មនេះទៀតសោត ប្រសិនជាគិតជាដំណាក់កាលវិញ វាមាន ៦ ដំណាក់កាល ដូចជា ការជ្រើសរើស ការទទួលយក ការសាយភាយ ការថែរក្សា ការបង្កើតកូត និង ការបង្កើតបញ្ញត្តិជាក្បួនខ្នាត (ចេន [Jenj] ២០០៧) ។

## ៣.១- ប្រទេសកម្ពុជា

ភាសាខ្មែរ គឺជាភាសាភាគច្រើនរបស់កម្ពុជា ដែលមានអ្នកនិយាយ ៩០ % ជាងនេះទៅទៀត ភាសាខ្មែរក៏មានវចនានុក្រមរបស់ខ្លួន ហើយ វចនានុក្រមថ្មីក៏កំពុងតែធ្វើបច្ចុប្បន្នភាព រីឯ សៀវភៅវេយ្យាករណ៍ ក៏មានច្រើនក្រាស់ក្រែលហើយដែរ ក៏ប៉ុន្តែ វេយ្យាករណ៍ភាគច្រើនពុំទាន់មានឯកភាពគ្នានៅឡើយ ។ សង្ឃឹមថា អនាគតកាល យើងនឹងមានវេយ្យាករណ៍ភាសាខ្មែរទំនើប និង ពិស្តារ ប្រកបដោយឯកភាព ដែលកើតឡើងពីកិច្ចសហការរបស់អ្នកប្រាជ្ញខាងភាសាខ្មែរ ។ ក្នុងន័យនេះ វិទ្យាស្ថានភាសាជាតិនៃរាជបណ្ឌិត្យសភាកម្ពុជា មានតួនាទីយ៉ាងសំខាន់ ក្នុងការសិក្សាស្រាវជ្រាវ និង រៀបចំវេយ្យាករណ៍ខ្មែរពិស្តារ ដោយមានកិច្ចសហការពីអ្នកប្រាជ្ញគ្រប់មជ្ឈដ្ឋាន ដើម្បីបម្រើសេចក្តីស្រេកឃ្លានខាងភាសា និង ដើម្បីលើកតម្កើងភាសាខ្មែរឱ្យមានកិត្យានុភាពក្នុងស្រទាប់មហាជន ។

សេចក្តីថ្លែងការណ៍រួម ចុះថ្ងៃទី ៥ ខែ កក្កដា ឆ្នាំ ១៩៦៧ បានបញ្ជាក់ថា ៖ « *ការប្រើភាសាខ្មែរជាផ្លូវការនឹងនាំឱ្យសាមគ្គីភាពរវាងពលរដ្ឋខ្មែរគ្រប់ជាន់ថ្នាក់ មានកំរិតកាន់តែខ្ពស់ឡើងទៀត ។ ការប្រើភាសាខ្មែរជាផ្លូវការ ពិតជាឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ នឹងសេចក្តីត្រូវការរបស់ស្ថានការណ៍ពន់ពេកណាស់* » (គណៈកម្មាធិការអចិន្ត្រៃយ៍ ១៩៦៧ ទំព័រ ៥) ។ តាមរយៈសេចក្តីថ្លែងការណ៍រួមនេះ ស្ថាប័នចម្រុះមួយបានបង្កើតឡើងដើម្បីសហការក្នុងការរៀបចំដោះស្រាយបញ្ហាដែលចោទឡើងក្នុងភាសាខ្មែរ ក្នុង

នោះ មាន បណ្ឌិតសភា គណៈកម្មការវប្បធម៌ សាកលវិទ្យាល័យនានា វិទ្យាស្ថានភាសា សមាគម រួមទាំង គណៈកម្មាធិការបច្ចេកទេសនានា រួមជាកម្លាំងធំមួយ ដើម្បីជំរុញអភិវឌ្ឍភាសាខ្មែរឱ្យមានវឌ្ឍនភាពឡើង ។ ចាប់តាំងពីការបង្កើតវិទ្យាស្ថានភាសាជាតិ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល តាមអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៩៨ ដែលកាលនោះ ស្ថាប័ននេះ ស្ថិតក្រោមអាណាព្យាបាលនៃក្រសួងអប់រំ យុវជន និង កីឡា ក៏ប៉ុន្តែក្រោយមក បានបញ្ចូលទៅក្នុងរាជបណ្ឌិត្យសភាកម្ពុជា តាមព្រះរាជក្រឹត្យលេខៈ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ហើយ ការបង្កើតវិទ្យាស្ថានភាសាជាតិនេះ មាន បេសកម្មសិក្សាស្រាវជ្រាវ អភិរក្ស និង អភិវឌ្ឍ ភាសានិងអក្សរសាស្ត្រខ្មែរ ភាសាមន-ខ្មែរដទៃទៀត ។ ដោយការខិតខំរបស់វិទ្យាស្ថានភាសាជាតិ ក្នុងការរៀបចំសិក្ខាសាលាស្តីពី «*ការស្រាវជ្រាវ ឯកភាព និងអភិវឌ្ឍន៍ ភាសាខ្មែរ លើកទី១ នៅឆ្នាំ២០០០ និង លើកទី២ នៅឆ្នាំ២០០៥*» (ព្រឹត្តិបត្រប្រចាំឆមាស លេខ១ ឆមាសទី១ ឆ្នាំ២០០៨ ទំព័រ ១)។ តាមរយៈសិក្ខាសាលាទាំងពីរលើកនេះ «គណៈកម្មាធិការជាតិភាសាខ្មែរ» បានបង្កើត ឡើង តាមរយៈអនុក្រឹត្យលេខ ១៨ អនក្រ. បក ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៧ ។ « *គណៈកម្មាធិការ ជាតិភាសាខ្មែរ មានភារកិច្ចកំណត់ឯកភាពនៃភាសាខ្មែរក្នុងការសរសេរ ការអាន និយមន័យ និងការបង្កើតពាក្យ ជាពិសេសកំណត់គោលនយោបាយជាតិនៃភាសា ដើម្បីអភិវឌ្ឍភាសាខ្មែរ ឱ្យចម្រើនឡើងប្រកបដោយនិរន្តរភាព និងរក្សានូវអត្តសញ្ញាណដ៏ថ្លៃថ្នូរ នៃជាតិខ្មែរ* » (ព្រឹត្តិបត្រប្រចាំឆមាស លេខ១ ឆមាសទី១ ឆ្នាំ២០០៨ ទំព័រ ៧)។ គណៈកម្មាធិការជាតិនេះ បានប្រែក្លាយទៅជា «ក្រុមប្រឹក្សាជាតិភាសាខ្មែរ» តាមព្រះរាជក្រឹត្យលេខ នស/រកត/០៦១១/៦០០ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១១ ។ តាមរយៈការបង្កើតស្ថាប័នទាំងពីរនេះ យើងឃើញថា វិទ្យាស្ថានភាសាជាតិ ជាស្ថាប័នសិក្សាស្រាវជ្រាវ នៅខណៈពេលដែល ក្រុមប្រឹក្សាជាតិភាសាខ្មែរ ជាស្ថាប័នពិគ្រោះផ្តល់យោបល់សម្រេចដើម្បីការប្រើប្រាស់ ភាសាខ្មែរ ។

### ៣.២- ប្រទេសសិង្ហបុរី

សិង្ហបុរី បានស្ថិតនៅក្រោមអាណានិគមរបស់ចក្រភពអង់គ្លេស ពីឆ្នាំ ១៩៤៦ ដល់ ១៩៦៣ ពីឆ្នាំ១៩៦៣ ដល់ ១៩៦៥ បានក្លាយជាដែនដីរបស់សហព័ន្ធម៉ាឡេ ស្ថិតក្នុងបូរណភាពរបស់ប្រទេសម៉ាឡេស៊ី ហើយ ក្រោយមកទទួលបានឯករាជ្យ នៅឆ្នាំ ១៩៦៥ ដែលមានឈ្មោះថា «សាធារណរដ្ឋសិង្ហបុរី» ដោយក្លាយ ជារដ្ឋទំនើប និង មានការអភិវឌ្ឍយ៉ាងឆាប់រហ័ស គួរឱ្យកត់សម្គាល់ ។ រដ្ឋាភិបាលសិង្ហបុរី បានបង្កើតគោល នយោបាយថ្មីមួយសម្រាប់អភិវឌ្ឍភាសារបស់ខ្លួន ដោយមានឈ្មោះថា «គោលនយោបាយពហុសាសន៍និយម (policy of multiracialism)» ពីព្រោះថា រដ្ឋសិង្ហបុរី កើតចេញពីជនជាតិបីសំខាន់ គឺ ជនជាតិចិន ៧៥ % ជនជាតិ ម៉ាឡេ ១៧ % និង ជនជាតិឥណ្ឌា និង មានភាសាបួនសំខាន់គឺ ភាសាចិន ភាសាម៉ាឡេ ភាសា អង់គ្លេស និង ភាសាតាមិល ។ មិនត្រឹមតែប៉ុណ្ណោះ រដ្ឋាភិបាល បានប្រកាសថា **ម៉ាឡេ** គឺត្រូវចាត់ទុកថា ជាភាសាជាតិរបស់សិង្ហបុរី (ស៊ីមសិន [Simpson] ២០០៧ ទំព័រ ៣៧៤)។ នៅឆ្នាំ ១៩៦៥ ភាសាអង់គ្លេស ត្រូវបានប្រើជា **មិស្សិតភាសា** (lingua franca) នៅប្រទេសសិង្ហបុរី រហូតដល់ទសវត្សឆ្នាំ ១៩៧០ ទន្ទឹមគ្នានេះ ផងដែរ ប្រទេសនេះ ប្រព័ន្ធអប់រំ បានផ្តល់ឱកាសដល់និស្សិតអាចជ្រើសរើសភាសាបានរហូតដល់ទៅពីរ ពោលគឺ ភាសាកំណើតរបស់ខ្លួន និង ភាសាទីពីរណាមួយ ។ នៅឆ្នាំ ១៩៧៨ ក្រសួងអប់រំ បានដាក់ចេញនូវគោល

នយោបាយអប់រំទ្វេភាសា ក៏ប៉ុន្តែ មិនបានទទួលជោគជ័យនោះទេ ពីព្រោះ មាននិស្សិតតែតិចជាង ៤០% ដែលទទួលចុះ ឈ្មោះសិក្សា ។

**៣.៣- ប្រទេសចិន**

ប្រព័ន្ធសំណេររបស់ចិន បានចាប់កំណើតឡើងតាំងពីឆ្នាំ ១៧០០ មុនគ្រឹស្តសករាជ (ចិន [Chen] ២០០៧ ទំព័រ ១៤១) ។ នៅសតវត្សទី២០ ចលនាភាសាជាតិបានកើតឡើង ក្នុងគោលបំណងជំរុញឱ្យមានភាសាស្តង់ដា ដើម្បីជំនួសស្តង់ដាសំណេរបុរាណរបស់ចិន ទីបំផុត ទំនើបនីយកម្មរបស់ចិនបានកើតឡើង គឺ សំណេរ និង អំណានភាសាចិនទំនើប ។ នៅឆ្នាំ ១៩២០ លក្ខណ៍សទ្ទតាកូតនីយកម្ម (codification-phonological features) បានបង្កើតឡើងដោយបានប្រមែប្រមូលពីយោបាយចិនដទៃទៀត ហើយ ទំបំផុត សទ្ទានុក្រមសំណេរនៅក្នុងការអានរបស់ជាតិមួយបានកើតឡើងនៅឆ្នាំ ១៩៣២ ដែលភាសាចិនហៅថា គ័រយិន ចាងយុង ស៊ីហួយ (Guoyin Changyong Zhihui) ។ ជាបណ្តើរៗ ភាសាចិនបានអភិវឌ្ឍមកត្រឹមទសវត្ស ឆ្នាំ ១៩៥០ ដោយបានប្តូរភាសាជាតិ **គ័រយូ** (guoyu) ទៅជា**ពុតុងហ័រ** (putonghua) វិញ ។

**៤- នយោបាយស្តង់ដានីយកម្ម** (Politics of Standardization)

ការបង្កើតនយោបាយស្តង់ដាភាសាឡើង គឺធ្វើយ៉ាងណាឱ្យអ្នកនិយាយភាសាផ្សេងៗក្នុងប្រទេសមួយ អាចប្រើភាសាមួយអាចយល់គ្នាបានទាំងអស់ ហើយ ម្នាក់ៗនឹងស្វែងរកអត្ថបទសំណេរ ឬ ការនិយាយគ្នា ដោយសប្បាយចិត្ត និង មានសីលធម៌ ។ ក្នុងស្ថានភាពនេះ បច្ចេកស័ព្ទមួយបានត្រូវប្រើដូចជា **ជាយក្លូសៀ** (diglossia) ដែលសំដៅទៅលើ « *ស្ថានភាពមួយដែលទម្រង់ពីរនៃភាសាដែលត្រូវគេចាត់ទុកថាសហវត្តមាននៃភាសាដូចគ្នាក្នុងទំនាក់ទំនងបរិបូណ៌ក្នុងសង្គមមួយ ។ ស្ថានភាពនេះរួមមានទម្រង់ខ្ពស់ និង ទម្រង់ទាប ។ ទម្រង់ខ្ពស់ ទាក់ទងទៅនឹងវប្បធម៌ដែលមានលក្ខណៈប្រសើរជាង ដោយសារទម្រង់នេះមាន អក្សរសិល្ប៍ ព័ត៌មានូបករណ៍ សុន្ទរកថា និង ការប្រលងសួង ។ ចំណែកឯ ទម្រង់ទាប សំដៅលើទម្រង់មិនផ្លូវការមួយរបស់ភាសាដែលទាក់ទងទៅនឹងបទពិសោធប្រចាំថ្ងៃដូចជា បទសន្ទនា និង ការនិទានរឿង ជាដើម* » (ស្វន និង អ្នកដទៃទៀត [Swann et al.] ២០០៤ ទំព័រ ៨២)។

តាមរយៈទិដ្ឋភាពនេះ យើងគួរស្វែងយល់អំពីភាពខុសប្លែកគ្នាអំពី ភាសា និង យោបាយ ។ ភាសា មានការវិវត្តជាង ដោយសារភាសា មានសំណេរ មានការអាន ជាពិសេសទៅទៀតនោះ ភាសា ធ្វើឱ្យមានការ ចាប់អារម្មណ៍ខ្លាំងខាងលក្ខណៈសម្បត្តិនៃការបញ្ចេញសំឡេង និង ខាងវេយ្យាករណ៍ ជាពិសេស ទិដ្ឋភាពភាសា មានវេយ្យាករណ៍ មានវចនានុក្រម ហើយ មានការបង្កើតសំណៅជាសៀវភៅកំណាព្យ ជាដើម ។ ដោយឡែក យោបាយ មានការវិវត្តយឺតយ៉ាវ មិនមានសំណេរតំណាងភាសារបស់ខ្លួន មិនត្រឹមតែប៉ុណ្ណោះ យោបាយមិនមាន វេយ្យាករណ៍ មិនមានវចនានុក្រម ឬ សៀវភៅស្តីអំពីកំណាព្យរបស់ខ្លួននោះទេ ។

## ៥- សន្និដ្ឋាន

សន្និដ្ឋានចុងក្រោយ សំណេរស្រាវជ្រាវនេះ នឹងបង្ហាញអំពីគោលគំនិតក្នុងការរៀបចំគោលនយោបាយភាសាជាតិ ភាសាផ្លូវការ ភាសាស្តង់ដា បណ្ឌិត្យសភាភាសា និងគំនិតផ្តួចផ្តើមកម្មវិធីសិក្សាអប់រំតាមរយៈភាសា។ ចំពោះប្រទេសកម្ពុជា ទោះបីជាមានផែនការរៀបចំវចនានុក្រមខ្មែរកាលពីឆ្នាំ ១៩១៥ យ៉ាងណាក៏ដោយ ក៏វចនានុក្រមនេះ បានលេចចេញជារូបរាងនៅឆ្នាំ ១៩២៧ ។ ក្រោយមក នៅឆ្នាំ ១៩៦៥ រាជបណ្ឌិតសភាបានបង្កើតឡើង ហើយ ក៏មានការបង្កើតឡើងវិញនៅឆ្នាំ ១៩៩៩ ដើម្បីសិក្សាស្រាវជ្រាវអំពីបញ្ហាសង្គមរបស់កម្ពុជា និង ផ្សារភ្ជាប់ពិភពលោក ជាពិសេស ដោះស្រាយបញ្ហាភាសាដែលចោទឡើងក្នុងសង្គមខ្មែរ ។ ចំណែក ប្រទេសសិង្ហបុរី អភិវឌ្ឍខ្លួនឱ្យទៅជារដ្ឋដែលជាសង្គមពហុភាសា ដោយជំរុញប្រព័ន្ធអប់រំទ្វេភាសា ក្នុងការលើកតម្កើងខ្លួនក្នុងឆាកអន្តរជាតិ ហើយ *សង្គមមួយនេះបានក្លាយទៅជាតម្លៃនិងអត្តសញ្ញាណវប្បធម៌របស់អាស៊ី* ។ ជាមួយគ្នានេះផងដែរ ប្រទេសចិន ដែលបានអភិវឌ្ឍខ្លួនក្លាយមកជាមហាយក្សចិន និងក្លាយជាមហាអំណាចសេដ្ឋកិច្ចទីពីរបន្ទាប់ពីសហរដ្ឋអាម៉េរិកនោះ បានចំណាយពេល ៣០ ឆ្នាំ ដើម្បីធ្វើឱ្យភាសារបស់ខ្លួនមានការរីកចម្រើន និង អភិវឌ្ឍ ។ ពោលគឺ ប្រទេសនេះ បានចំណាយពេល នៅទសវត្សឆ្នាំ១៩២០ រហូតដល់ ទសវត្សឆ្នាំ ១៩៥០ ដែលកាលនោះ មាននយោបាយភាសាជាច្រើនពុំទាន់មានឯកភាព ហើយ ក៏ក្លាយជាប្រទេសមានភាសារួម គឺចិនកុងងឺសម្រាប់សង្គមជាតិទាំងមូល ។

និយាយជារួម ភាសាគឺជាមធ្យោបាយក្នុងការបង្ហាញគំនិត ការបញ្ចេញគំនិត និង ការទាក់ទងគ្នាពីមនុស្សម្នាក់ទៅម្នាក់ទៀត ។ ភាសា ក៏អាចជាភាពចម្រូងចម្រាស់ខាងផ្នែកនយោបាយផងដែរ ពីព្រោះថា ភាសាជាផ្នែកដ៏ធំមួយរបស់នយោបាយ ហើយ ការប្រើប្រាស់ភាសាឱ្យមានឯកភាព ក៏ត្រូវមានផែនការច្បាស់លាស់ និង មានគោលនយោបាយភាសាមួយ ដើម្បីនាំឆ្ពោះទៅរកការអភិវឌ្ឍ ។ ការនាំឱ្យមានផែនការភាសាមួយ គឺជាការបង្កើតស្តង់ដាភាសាមួយដើម្បីគាំទ្រភាសាជនជាតិភាគតិច ភាសាជនជាតិដើមភាគតិច ជាពិសេស ការបង្កើតឱ្យមានប្រព័ន្ធមួយប្រកបដោយវិទ្យាសាស្ត្រ និង សម្បូរបែប ក្នុងការបម្រើសេចក្តីត្រូវការរបស់មនុស្ស និង សង្គមជាតិ ក្នុងការប្រើប្រាស់ភាសា ប្រកបដោយបច្ចេកវិទ្យាទំនើប ។ មួយវិញទៀត ការជំរុញការស្រាវជ្រាវខាងផ្នែកភាសា និង មូលនិធិគាំទ្រអភិវឌ្ឍភាសា ក៏ជាការចាំបាច់ផងដែរ ដើម្បីអភិវឌ្ឍកម្រងទិន្នន័យភាសា វចនានុក្រមវេយ្យាករណ៍ និង ប្រព័ន្ធអក្ខរាវិរុទ្ធឱ្យមានឯកភាព ។